**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៣៣៤៣អយក.ហវ

ថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៥

**ជម្រាបជូន**

**-លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**
**-លោក លោកស្រីប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

**កម្មវត្ថុ ៖** ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ «ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ» ដែលបានផ្ទេរទៅថ្នាក់ក្រោមជាតិ។

**យោង ៖** - អនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- ប្រកាសអន្តរក្រសួងលេខ ៣៤៥ សហវ.ប្រក.អថ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សារាចរលេខ ០០២ សហវ.ស.រ.អរតន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រីប្រធាន** ជ្រាបថា៖ នៅឆ្នាំ ២០២០ ក្រសួងបានផ្ទេរថវិកាទៅរដ្ឋបាលក្រុង ស្រុក នៅខេត្តបាត់ដំបង តាមរយៈស្មារតីនៃអនុក្រឹត្យលេខ១៨២ អនក្រ.បក ១៨៣ អនក្រ.បក និង១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ និងប្រកាសអន្តរក្រសួងលេខ ៥២១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ នៅឆ្នាំ២០២៤ ក្រសួងក៏បានផ្ទេរថវិកាមុខងារការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងការគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ក្នុងក្របខណ្ឌទូទាំងប្រទេសទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមស្មារតីនៃអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុដែលបានផ្ទេរនេះ ប្រកបដោយប្រសិទ្ធភាព គណនេយ្យ និងតម្លាភាព ក្រសួងបានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានផ្ទេរទៅថ្នាក់ក្រោមជាតិ មានលក្ខណៈជា Web Application (Online) បានបញ្ចប់សព្វគ្រប់ ក្នុងគោលបំណងបង្កើនស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបបច្ចេកវិទ្យា ស្របទៅនឹងការវិវត្តរបស់សង្គមនិងសេដ្ឋកិច្ចឌីជីថលបច្ចុប្បន្ន ជាពិសេសប្រព័ន្ធមានសមត្ថភាពសម្រាប់ការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ បង្កើតកិច្ចបញ្ជិកាគណនេយ្យ កិច្ចបញ្ជិកាគណនេយ្យសម្ភារៈ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សម្រាប់ទូទាត់ ព្រមទាំងបូកសរុបការចំណាយលើការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេសបានទាន់ពេលវេលា និងមានប្រសិទ្ធភាពជាស្វ័យប្រវត្តិកម្ម ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ជាក់ស្តែងរបស់ក្រសួង និងស្របជាមួយនឹងគោលការណ៍ច្បាប់គតិយុត្ត។ ក្នុងន័យនេះ ក្រសួងសូមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ប្រើប្រាស់ជាផ្លូវការចាប់ពីឆ្នាំ២០២៥ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រីប្រធាន** មេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម **លោក លោកស្រីប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គលេខាធិការដ្ឋាន
- រដ្ឋបាលរាជធានី ខេត្ត
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ